# ស្គរខ្មែរតាមរយៈរូបតំណាងលើជញ្ជាំងប្រាសាទអង្គរ

នៅក្នុងអត្ថបទនេះ ខ្ញុំប្រើពាក្យ «ប្រាសាទអង្គរ» ដោយសំដៅទៅលើប្រាសាទបុរាណខ្មែរ នៅក្នុង «តំបន់អង្គរ» គឺមិនត្រឹមតែប្រាសាទអង្គរវត្តតែមួយប៉ុណ្ណោះទេ ដែលមានចម្លាក់និងរូបតំណាងពីឧបករណ៍តន្ត្រីស្គរខ្មែរជាច្រើនប្រភេទ។ ម្យ៉ាងទៀត ខ្ញុំមានគោលបំណងចង់បញ្ជាក់អំពីការមើលច្រឡំ ឬ ហៅច្រឡំ «ស្គរយោល» ថាជា «សម្ភោរ» ជាដើម ដោយសារតែស្គរទាំងពីរប្រភេទនេះ មានមុខពាសស្បែកពីរដូចគ្នា ហើយប្រើដៃពីរដើម្បីនឹងវាយដូចគ្នា។ នៅក្នុងចំណាត់ថ្នាក់តន្ត្រីអន្តរជាតិ (organology) ស្គរយោល ជាប្រភេទស្គរ (cylindrical drum) ដែលមានរាងស៊ីឡាំង ឯសម្ភោរ (barrel drum) មានរាងជាធុងប៉ោងធំនៅចំកណ្ដាលតួស្គរ ដូច្នេះយើងមិនគួរច្រឡំឡើយ។

ខ្ញុំបានសរសេរនៅក្នុងអត្ថបទពាក់ព័ន្ធនឹងឧបករណ៍តន្ត្រីបុរាណខ្មែរ ដែលបុព្វបុរសខ្មែរយើង លោកបានឆ្លាក់នៅលើជញ្ជាំងប្រាសាទអង្គរពីមុនរួចមកហើយ រួមមានឧបករណ៍តន្ត្រី ម៉ិម ពិណ ខ្សែ១ ស័ង្ខ ស្នែង ត្រែ ស្រឡៃ ខ្លុយ ពាទ្យ គងញី (គងដោះ) គងឈ្មោល (គងរាប) គងតូច គងធំ ឈឹង ឆាប ដួង កណ្ដឹង ថូន ស្គរដៃ ស្គរយោល ស្គរភ្លោះ ស្គរឈ្នះ សាំងណា សម្ភោរ ស្គរធំ និងស្គរជ័យ។

នៅក្នុងអត្ថបទនេះ ខ្ញុំសូមលើកយកតែឧបករណ៍ស្គរមកអធិប្បាយតែប៉ុណ្ណោះរួមមាន ថូន ស្គរដៃ ស្គរយោល ស្គរឈ្នះ សម្ភោរ ស្គរធំ និងស្គរជ័យ។ គេចែកស្គរទាំងនេះជាបីប្រភេទគឺ៖ ១) ប្រភេទដែលមានរូបរាងជាថូឬកែវ (goblet drum) ២) ប្រភេទមានរាងស៊ីឡាំង (cylindrical drum) និង៣)ប្រភេទមានរាងជាធុងប៉ោងធំ នៅចំកណ្ដាលតួស្គរ (barrel drum)។

តាមការពិនិត្យ ខ្ញុំឃើញថារូបភាព ចម្លាក់ និងរូបតំណាងខ្លះ ជារូបប្រាកដនិយម បកស្រាយពីសេចក្ដីពិតនៃជីវិតនិងសកម្មភាពជាក់ស្ដែង ឯខ្លះទៀត ជារូបនិមិត្តសញ្ញា ព្រោះគ្មានភាពជាក់ស្ដែងឬប្រាកនិយម។ លើសពីនេះទៅទៀត ខ្ញុំក៏សូមធ្វើការកត់សម្គាល់ថា ជាពិសេសចម្លាក់និងរូបតំណាងនៅលើជញ្ជាំងប្រសាទអង្គរវត្ត ថែវខាងជើង លាតត្រដាងបង្ហាញអំពីក្បួនព្យុហយាត្រាដែលមាន១៤ផែន ដូចដែលសិល្បករនិង សិល្បការិនីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈធ្លាប់បានតម្លើងនិងសម្ដែងទទួលលោកប្រធានាធិបតី ហាឡេសេឡាស្សេ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

នៃប្រទេសអេធីយូពី លោកស្យាល ដឺហ្គោល ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង និងនៅពេលថ្មីៗនេះនៅក្នុងព្រឹត្តិការណ៍ «អង្គរឃ្យុងយូ» ដែលខ្លួនខ្ញុំផ្ទាល់បានធ្វើជាពិធីករ។ រូបភាពជាក្បួនព្យុហយាត្រា១៤ផែន តំណាងនិងលាតត្រដាងអំពីស្នាដៃដ៏មហិមានិងភាពជោគជ័យដ៏អស្ចារ្យរបស់ខ្មែរនាសម័យអង្គរដ៏រុងរឿង។

នៅក្នុងបរិបទនេះ ស្គរមុខពីរនិងសម្ភោរព្យួរនៅនឹងក គឺមិនខុសគ្នាពីព្យុហយាត្រានៅក្នុងព្រះបរមរាជវាំងនាពេលបច្ចុប្បន្ន ក្នុងព្រះរាជពិធីអភិសេក ព្រះរាជពិធីសព និងនៅទីលានវាលព្រះមេរុ ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លជាដើម។ ដូច្នេះ ស្គរមួយចំនួននិងសម្ភោរព្យួរនៅកជាកត្តាបរិបទព្យុហយាត្រា៕



រូបលេខ១៖ ស្គរមានរូបរាងជាថូឬកែវ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



រូបលេខ២៤៖ សម្ភោរ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



រូបលេខ២៣៖ ស្គរធំ



រូបលេខ២៤៖ ស្គរយោល



រូបលេខ២៥៖ ស្គរយោលមុខពីរ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## ឯកសារយោង


Kersalé, Patrick. (August 25, 2021). *Reviving the Musical Instruments of Khmer Empire*.

Nicolas, Arsenio. (2021). *Musical Instruments on the 16th Century Bas-Reliefs in the North Gallery-East Wing of Angkor Wat: Dating and Significance*. The SEAMEO SPAFA International Conference on Southeast Asian Archeology and Fine Arts.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.